# គោលនយោបាយស្តីពីការគ្រប់គ្រងដីរដ្ឋ

**ខែវិច្ឆិកា ឆ្នាំ ២០០៤**

**ក្រុមប្រឹក្សាគោលនយោបាយដីធ្លី**

**ក្រុមការងារគ្រប់គ្រងដីរដ្ឋ**

(កែតម្រូវតាមស្មារតីនៃអង្គប្រជុំក្រុមប្រឹក្សាគោលនយោបាយដីធ្លី ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៤)

# គោលនយោបាយសំរាប់ការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ

## ផ្នែកទី ១ : ការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ

ដីរដ្ឋត្រូវបានចែងនៅក្នុងជំពូកទី២នៃច្បាប់ភូមិបាលឆ្នាំ២០០១ ដោយបានបែងចែកជា ដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ។ ដីរដ្ឋត្រូវបានបែងចែកជាច្រើនប្រភេទសំរាប់បំរើផលប្រយោជន៍សាធារណៈ។ ដើម្បីគ្រប់គ្រងទ្រព្យទាំងនេះបាន រដ្ឋត្រូវមានផែនទី/ប្រព័ន្ធទិន្នន័យ ក្នុងការកំណត់ទីតាំង ធ្វើ អត្តសញ្ញាណ-កម្ម និងធ្វើចំណាត់ថ្នាក់ដីទាំងនោះ ជាដីសាធារណៈរបស់រដ្ឋ ឬ ជាដីឯកជនរបស់រដ្ឋ។ មានតែមធ្យោបាយនេះទើបរដ្ឋអាចដឹងច្បាស់ពីទីកន្លែងដែលទ្រព្យរដ្ឋទាំងនោះតាំងនៅ អាចធ្វើផែនការប្រើប្រាស់ និងគ្រប់គ្រងទ្រព្យទាំងនោះដោយតម្លាភាព និងអាចកំណត់អាជ្ញាធរគ្រប់គ្រងបានត្រឹមត្រូវ។

អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ នឹងចែងអំពីការធ្វើអត្តសញ្ញាណកម្ម ការកសាងផែនទី និង ការធ្វើចំណាត់ថ្នាក់ដីរដ្ឋ។ ការចុះបញ្ជីដីរដ្ឋនឹងត្រូវអនុលោមតាមអនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី លេខ ៤៦អនក.បក ចុះថ្ងៃ៣១ ខែឧសភាឆ្នាំ ២០០១ និងអនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីជាលក្ខណៈដាច់ដោយដុំ លេខ ៤៨អនក.បក ចុះថ្ងៃ៣១ ខែឧសភាឆ្នាំ ២០០១។

**ការធ្វើអត្តសញ្ញាណកម្ម និងការកសាងផែនទីដីរដ្ឋ** គឺជាដំណើរការសំរបសំរួលមួយ ដែលទីតាំង និងព្រំប្រទល់ប្រហាក់ប្រហែលនៃដីរដ្ឋត្រូវបានកំណត់ជាលក្ខណៈប្រព័ន្ធ និងមានរៀបចំឯកសារទៅតាមការតវ៉ាទាមទាររបស់អាជ្ញាធរទទួលខុសត្រូវ។ ក្នុងដំណើរការនេះ ចំណាត់ថ្នាក់ដំបូងនៃដីរដ្ឋជាច្រើននឹងត្រូវបានបញ្ជាក់ទៅតាមការប្រើប្រាស់ជាក់ស្តែង។ នីតិវិធីនេះនឹងត្រូវបញ្ចប់ដោយមានភ្ជាប់នូវផែនទីបង្ហាញពីការតវ៉ារបស់អាជ្ញាធរផ្សេងៗ។ លទ្ធផលនៃការធ្វើអត្តសញ្ញាណកម្ម និងការកសាងផែនទី នឹងត្រូវបានបញ្ចូលទៅក្នុងផែនទី ឬប្រព័ន្ធទិន្នន័យដីរដ្ឋ ដែលនឹងបង្កើតឡើងដោយអនុក្រឹត្យ។

ការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ ត្រូវស្ថិតក្រោមការណែនាំបច្ចេកទេសរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ហើយការអនុវត្តការងារ ត្រូវស្ថិតក្រោមការដឹកនាំរបស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ ខេត្តក្រុង (PSLMC)។ ក្នុងគោលដៅនេះ ក្រុមការងារដីរដ្ឋនឹងត្រូវបង្កើតនៅតាមស្រុកខ័ណ្ឌជាក់លាក់នីមួយៗ ដើម្បីអនុវត្តការងារជាជាក់ស្តែង។ ក្រុមការងារនេះនឹងត្រូវដឹកនាំដោយអភិបាលស្រុក ខណ្ឌ ហើយស្ថាប័ននានាដែលមានការពាក់ព័ន្ធនឹងដីរដ្ឋនៅក្នុងស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំសង្កាត់ និងរដ្ឋបាលសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវចូលរួមក្នុងក្រុមការងារនេះ។

យ៉ាងណាក៏ដោយ ដំណើរការនេះមិនពាក់ព័ន្ធនឹងសិទ្ធិឯកជនឡើយ។ ពតិមានអំពីឯកជនកាន់កាប់ដី ដែលសន្មត់ថាជាដីរដ្ឋ នឹងត្រូវបានប្រមូលទុក។ ប៉ុន្តែ ក្នុងរយៈពេលដំណើរការធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋ សិទ្ធិកាន់កាប់នេះមិនត្រូវបានសម្រេចថាស្របច្បាប់ ឬមិនស្របច្បាប់ឡើយ។ ការសម្រេចនឹងត្រូវបានធ្វើនៅពេលធ្វើការចុះបញ្ជី។

## ផ្នែកទី ២ : ការចុះបញ្ជី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ

**ការចុះបញ្ជីដីរដ្ឋ** គឺជានីតិវិធីមួយដែលទីតាំង និងព្រំប្រទល់នៃដីរដ្ឋត្រូវបានបញ្ជាក់ជាផ្លូវការ។ នៅក្នុងការចុះបញ្ជី សិទ្ធិឯកជនត្រូវបានលើកមកពិចារណា និងវិនិច្ឆ័យ ហើយទំនាស់នឹងត្រូវបានដោះស្រាយដោយគណៈកម្មការរដ្ឋបាល ឬគណៈកម្មការសុរិយោដី។ មុនពេលធ្វើការចុះបញ្ជី ពតិមាននៃផែនទី និងប្រព័ន្ធទិន្នន័យដីរដ្ឋ គឺជាពតិមានបឋម និងមិនទាន់បានបញ្ជាក់នៅឡើយ។

**ចំណាត់ថ្នាក់ដីរដ្ឋជាផ្លូវការ** អាចត្រូវបានធ្វើបន្ទាប់ពីការចុះបញ្ជីឋានៈរបស់ដី ដែលបញ្ជាក់ថាជាដីរដ្ឋ។ ការចុះបញ្ជីមានន័យថា :

ក) កំណត់ផលប្រយោជន៍សាធារណៈជាក់លាក់ណាមួយ ដែលដីរដ្ឋសាធារណៈ អាចបំពេញមុខងារស្របទៅតាមច្បាប់ភូមិបាល

ខ) កំណត់ថាត្រូវធ្វើចំណាត់ថ្នាក់ដីរដ្ឋយ៉ាងណា ឱ្យច្បាប់ព្រៃឈើ ច្បាប់គ្រប់គ្រងធនធានទឹក ឬសេចក្តីព្រាងច្បាប់តំបន់ការពារ ច្បាប់ស្តីពីតំបន់បេតិកភ័ណ្ឌបុរាណវត្ថុ និងច្បាប់ផ្សេងៗទៀត អាចបានស្របគ្នា និង

គ) កំណត់ឋានៈរបស់ដី ជាដីសាធារណៈរបស់រដ្ឋ ឬ ជាដីឯកជនរបស់រដ្ឋ។ មានតំបន់ជាច្រើនដែលការធ្វើចំណាត់ថ្នាក់នេះមានភាពច្បាស់លាស់ តាមការប្រើប្រាស់កន្លងមក និងការសម្របសំរួលការគ្រប់គ្រង។ ប៉ុន្តែ ក្នុងតំបន់មួយចំនួន ការកំណត់នេះមិនទាន់ច្បាស់លាស់ ហើយត្រូវតែធ្វើឡើងនៅក្នុងដំណើរការនៃការធ្វើអត្តសញ្ញាណកម្ម ធ្វើផែនទី និង ធ្វើចំណាត់ថ្នាក់ដីរដ្ឋ។

ប្រភេទជាក់លាក់មួយចំនួនក្នុងការធ្វើចំណាត់ថ្នាក់ដី ត្រូវបានបង្កើតឡើងនៅក្នុងច្បាប់ផ្សេងៗនៃព្រះរាជាណាចក្រកម្ពុជា។ ភាពចាំបាច់ក្នុងការធ្វើអត្តសញ្ញាណកម្ម ធ្វើផែនទី និងធ្វើចំណាត់ថ្នាក់ដីរដ្ឋ គឺមានបំណងភ្ជាប់ចំណាត់ថ្នាក់ជាផ្លូវការទាំងនេះទៅនឹងទីតាំងជាក់ស្តែងលើផ្ទៃដី។

ក្នុងជំពូកទី ២ ពីមាត្រា ១២ ដល់ ១៦ នៃច្បាប់ភូមិបាល មានចែងអំពីការធ្វើចំណាត់ថ្នាក់ដី ជាប្រភេទទ្រព្យសាធារណៈរបស់រដ្ឋ និងទ្រព្យឯកជនរបស់រដ្ឋ។ មាត្រា ១៥ នៃច្បាប់ភូមិបាលឆ្នាំ ២០០១ បានកំណត់ដីសាធារណៈរបស់រដ្ឋជាប្រាំពីរប្រភេទ។ ដីឯកជនរបស់រដ្ឋ គឺជាដីទាំងឡាយណាដែលមិនត្រូវបានកាន់កាប់ជាលក្ខណៈឯកជន។ នៅក្នុងប្រភេទដីសាធារណៈរបស់រដ្ឋ មានប្រភេទបន្ទាប់បន្សំជាក់លាក់ផ្សេងៗទៀត ដែលមានចែងនៅក្នុងបញ្ញត្តិច្បាប់តាមវិស័យនានា ដូចជាច្បាប់ព្រៃឈើ និងសេចក្តីព្រាងផ្សេងៗ ដូចជាច្បាប់ជលផលច្បាប់គ្រប់គ្រងធនធានទឹក និងច្បាប់ស្តីពីតំបន់ការពារ។

- *ដីព្រៃគឺជាប្រភេទចំបងនៃដីសាធារណៈរបស់រដ្ឋ ដែលមានចែងលំអិតនៅក្នុងច្បាប់ព្រៃឈើ។ ច្បាប់ព្រៃឈើបានកំណត់ឱ្យមានដីព្រៃអចិន្ត្រៃយ៍ ដែលមានមួយចំណែកជារបស់រដ្ឋហៅថាព្រៃបំរុងទុកអចិន្ត្រៃយ៍ និងមួយចំណែកទៀតជារបស់ឯកជន ហៅថាព្រៃឯកជន។ ព្រៃបំរុងទុកអចិន្ត្រៃយ៍របស់រដ្ឋមានបីប្រភេទ ដែលជាដីព្រៃរបស់រដ្ឋ។ ដីព្រៃបំរុងទុកអចិន្ត្រៃយ៍របស់រដ្ឋមួយចំនួនអាចចាត់ជាព្រៃសហគមន៍។ នៅក្នុងចំណាត់ថ្នាក់ដីព្រៃបំរុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ប្រភេទដីព្រៃសំរាប់ផ្ទេរ គឺទុកប្រើប្រាស់ដើម្បីគោលដៅអភិវឌ្ឍន៍ផ្សេងៗ។ ដីព្រៃសំរាប់ផ្ទេរត្រូវបានកំណត់ថាជា "ដីទំនេររបស់រដ្ឋ" រួមមានព្រៃបន្ទាប់បន្សំ ដែលមិនទាន់កំណត់ការប្រើប្រាស់ដោយវិស័យណាមួយ នឹងត្រូវធ្វើចំណាត់ថ្នាក់ជាបណ្តោះអាសន្នថាជាព្រៃបំរុងទុកអចិន្ត្រៃយ៍ រហូតដល់រាជរដ្ឋាភិបាលចាត់ចែងដីនោះសំរាប់ការប្រើប្រាស់ជាក់លាក់ និងក្នុងគោលដៅណាមួយ។ ម្យ៉ាងទៀត ដីរដ្ឋនេះត្រូវបានចាត់ថ្នាក់ជាដីព្រៃបំរុងទុកអចិន្ត្រៃយ៍ជាបណ្តោះអាសន្នតែប៉ុណ្ណោះ។ គោលនយោបាយនៃការធ្វើអត្តសញ្ញាណកម្ម ធ្វើផែនទី និងចំណាត់ថ្នាក់ដីរដ្ឋ នឹងប្រើជាផែនទីជាតិសំរាប់អនុវត្តច្បាប់ព្រៃឈើ និងជួយដល់ការធ្វើសមាហរណកម្មប្រភេទព្រៃបំរុងទុកអចិន្ត្រៃយ៍ ទៅក្នុងសមាហរណកម្មប្រព័ន្ធពតិមាននៃការធ្វើចំណាត់ថ្នាក់ដីរដ្ឋ។ ដីព្រៃគឺប្រភេទដីរដ្ឋដែលមានទំហំធំជាងគេ។*
- *សេចក្តីព្រាងច្បាប់ស្តីពីតំបន់ការពារ ក៏បានកំណត់ផងដែរនូវប្រភេទដីសាធារណៈរបស់រដ្ឋ និងដីដែលអាចជាដីឯកជន ប៉ុន្តែក៏មានការកំរិតការប្រើប្រាស់សំរាប់ការការពារបរិស្ថាន។ សេចក្តីព្រាងច្បាប់នេះបានកំណត់តំបន់ការពារចំនួន ១១ ប្រភេទ ដែលនឹងត្រូវធ្វើអត្តសញ្ញាណកម្ម ធ្វើផែនទី និងធ្វើចំណាត់ថ្នាក់។*
- *ផ្លូវថ្នល់ក៏ទាមទារឱ្យមានធ្វើអត្តសញ្ញាណកម្ម ធ្វើផែនទី និងធ្វើចំណាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋដែរ។*
- *សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក និយាយសំដៅទៅលើប្រភេទនៃដីរដ្ឋដែលបានចែងនៅក្នុងច្បាប់ភូមិបាល (ផ្លូវទឹក ច្រាំងទន្លេ បឹងធម្មជាតិ និងឆ្នេរសមុទ្រ) និងបានឱ្យនិយមន័យបន្ថែមលើពាក្យ "ច្រាំង និង ឆ្នេរ" ដោយផ្អែក លើតំបន់លិចទឹកជាធម្មតា ឬលិចទឹកម្តងម្កាល។ ដូច្នេះការ*

*ធ្វើចំណាត់ថ្នាក់ដីរដ្ឋនៅក្នុងប្រភេទនេះ គួរតែត្រូវបានធ្វើអត្តសញ្ញាណកម្ម ធ្វើផែនទី ធ្វើចំណាត់ថ្នាក់ និងបន្ថែមព័ត៌មានអំពីតំបន់ដីរដ្ឋដែលរងការលិចទឹក ។*

- *ប្រភេទដីសាធារណៈរបស់រដ្ឋផ្សេងទៀត រាប់បញ្ចូលទាំងការប្រើប្រាស់ជាទូទៅដូចជាកំពង់ផែ និងព្រលានយន្តហោះ សំភារៈនៃសេវាសាធារណៈ តំបន់បេតិកភ័ណ្ឌបុរាណវិទ្យា និងព្រះរាជទ្រព្យ ក៏ត្រូវកំណត់ឱ្យបានច្បាស់ផងដែរ ។ សម្បទានព្រៃដែលមានស្រាប់ សម្បទានសំរាប់គោលដៅកសិកម្ម និងគោលដៅផ្សេងទៀតដូចជាការរុករករ៉ែ ក៏ទាមទារឱ្យធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដែរ ។ ប្រភេទនៃតំបន់យោធាគឺជាប្រភេទដីបន្ទាប់បន្សំនៃសេវាសាធារណៈដែលពុំទាន់មានការកំណត់ច្បាស់លាស់នៅក្នុងច្បាប់ ក៏នឹងបញ្ជាក់ឱ្យបានច្បាស់សំរាប់ការធ្វើអត្តសញ្ញាណកម្ម ធ្វើផែនទី និងធ្វើចំណាត់ថ្នាក់ដែរ ។*

បន្ទាប់ពីបានធ្វើការពិនិត្យប្រភេទផ្សេងៗនៃដីរដ្ឋឡើងវិញរួចហើយ ឃើញថាព័ត៌មានជាក់លាក់ជាច្រើនដែលស្ថិតនៅនឹងមូលដ្ឋាន ជាសេចក្តីត្រូវការចាំបាច់សម្រាប់ការធ្វើអត្តសញ្ញាណកម្ម ធ្វើផែនទី និងធ្វើចំណាត់ថ្នាក់ដីរដ្ឋកំពុងកាន់កាប់ ។ ពតិមានទាំងនេះមានលក្ខណៈចាំបាច់សម្រាប់ការអនុវត្តច្បាប់ភូមិបាល ច្បាប់ព្រៃឈើ សេចក្តីព្រាងច្បាប់ស្តីពីតំបន់ការពារ ។ ពតិមានជាច្រើនអាចរកបានពីស្ថាប័នថ្នាក់ជាតិ ថ្នាក់ខេត្តក្រុង និងស្រុក ខណ្ឌ ប៉ុន្តែមានពតិមានជាច្រើនទៀតនឹងបានមកពីប្រភពមូលដ្ឋាន ។ ដូច្នេះ គោលនយោបាយធ្វើនិយ័តកម្មដីរដ្ឋ មិនអាចគ្រាន់តែផ្អែកលើពតិមានដែលមានស្រាប់នៅតាមស្ថាប័នថ្នាក់ជាតិទេ ។ ការចូលរួមរបស់អ្នកស្រុកនៅមូលដ្ឋាន ក្នុងការធ្វើអត្តសញ្ញាណកម្ម ធ្វើចំណាត់ថ្នាក់ និងការចុះបញ្ជី ជាប្រការចាំបាច់ ។

គោលការណ៍ជាមូលដ្ឋាននៅក្នុងច្បាប់ភូមិបាល គឺមានតែតំបន់ដែលត្រូវការប្រើសំរាប់ជាប្រយោជន៍សាធារណៈជាក់លាក់ទេ ដែលនឹងត្រូវបានទទួលស្គាល់ជាដីសាធារណៈរបស់រដ្ឋ ។ រដ្ឋទទួលខុសត្រូវក្នុងការបង្ហាញពីសេចក្តីត្រូវការចាំបាច់របស់រដ្ឋចំពោះដី ដើម្បីបំពេញគោលដៅនៃការប្រើប្រាស់ជាសាធារណៈជាក់លាក់ណាមួយ ដូចបានកំណត់ក្នុងច្បាប់ភូមិបាល ។ តំបន់ផ្សេងៗទៀតដែលមិនមានតម្រូវការច្បាស់លាស់សម្រាប់គោលដៅសាធារណៈជាក់លាក់ទេ នឹងត្រូវបានធ្វើចំណាត់ថ្នាក់ជាដីឯកជនរបស់រដ្ឋ ។ រាល់ការធ្វើអត្តសញ្ញាណកម្ម និងការធ្វើចំណាត់ថ្នាក់ដីនៅក្នុងតំបន់ណាមួយ គួរត្រូវមានការព្រមព្រៀងពីគ្រប់ស្ថាប័ន និងពីអ្នករស់នៅក្នុងមូលដ្ឋាន ។ ការងារនេះត្រូវតែធ្វើនៅនឹងកន្លែងតែម្តង ដោយមានការចូលរួមពីអ្នកស្រុកមូលដ្ឋាន ដើម្បីឈានដល់ការសម្រេចប្រកបដោយយុត្តិធម៌ និងជានិរន្តរ៍ ។

អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ នឹងកំណត់នីតិវិធីនៃការធ្វើចំណាត់ថ្នាក់ដី និងចែងអំពីការធ្វើការសម្រេចចិត្ត ។ ការធ្វើ ចំណាត់ថ្នាក់ដីត្រូវតែផ្អែកលើការប្រកាសដែលបានធ្វើឡើងដោយអាជ្ញាធរនានា

នៅក្នុងពេលធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទី ប្រសិនបើមានធ្វើរួចហើយ។ បើពុំដូច្នោះទេ នីតិវិធីដូចគ្នានេះនឹងត្រូវរៀបចំធ្វើ នៅក្នុងពេល ធ្វើចំណាត់ថ្នាក់ដី។ ក្នុងដំណើរការធ្វើចំណាត់ថ្នាក់ដី PLUAC នឹងត្រូវធ្វើការស៊ើប អង្កេតលើការប្រកាសរបស់ អាជ្ញាធរ ដោយផ្អែកលើទស្សនៈច្បាប់ និងព្យាយាមសំរបសំរួលអំពីបញ្ហាគ្រប់គ្រងត្រួតគ្នាដែលអាចមាន។ ប្រសិនបើពុំអាចឈានដល់ការស្រុះស្រួលគ្នា ករណីគ្រប់គ្រងត្រួតគ្នានេះនឹងត្រូវដាក់ជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លីដើម្បីធ្វើការសំរុះសំរួល ហើយបើមិនមានការព្រមព្រៀងទៀត ករណីនេះនឹងត្រូវដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីធ្វើការសំរេចជាចុងក្រោយ។

## ផ្នែកទី ៣ : ផែនទី ឬ ប្រព័ន្ធទិន្នន័យដីរដ្ឋ

ផែនទី ឬ ប្រព័ន្ធទិន្នន័យដីរដ្ឋ គឺជាទិន្នន័យសាធារណៈមួយ ដែលក្នុងនោះ ពត៌មានទាំងអស់អំពីទីតាំង និងលក្ខណៈនៃដីរដ្ឋត្រូវបានដាក់បញ្ចូល។ ផែនទី ឬ ប្រព័ន្ធទិន្នន័យនេះបំពេញបន្ថែមលើបញ្ជីសារពើភ័ណ្ឌទ្រព្យរដ្ឋ ដែលគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ផែនទី ឬប្រព័ន្ធទិន្នន័យដីរដ្ឋនេះ នឹងមានផ្ទុកពត៌មានដែលមិនទាន់បានបញ្ជាក់ច្បាស់ និងមិនផ្លូវការ ដែលបានមកពីការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទី ព្រមទាំងពត៌មានដែលបានបញ្ជាក់ច្បាស់ហើយ ដោយផ្អែកលើការចុះបញ្ជី និងការធ្វើចំណាត់ថ្នាក់។

មុននឹងធ្វើការចុះបញ្ជី និងធ្វើចំណាត់ថ្នាក់ ពត៌មានដែលបានមកពីការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ មិនមែនជាកំណត់ត្រាគ្មានទំនាស់អំពីកម្មសិទ្ធិ និងមិនមានតម្លៃស្មើនឹងការចុះបញ្ជីនោះទេ។ ទោះជាយ៉ាងណា ពត៌មាននេះមានតម្លៃតាមផ្លូវច្បាប់ ដើម្បីអនុវត្តមាត្រា ១៧ នៃច្បាប់ភូមិបាល ដែលចែងថា គ្មានការចាប់យកដីរដ្ឋតាមទំនើងចិត្តទៀតឡើយ។ ព័ត៌មាននេះអាចនឹងជួយដល់អ្នកប្រើប្រាស់ដីរដ្ឋជាច្រើន ដោយជំរុញដល់ការអនុវត្តមាត្រា ២២៦ នៃច្បាប់ភូមិបាល ដែលចែងថា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ជាអ្នកទទួលខុសត្រូវក្នុងការ "ធ្វើអត្តសញ្ញាណកម្មទ្រព្យ និងផ្តល់ពត៌មានដល់ជនទាំងឡាយអំពីស្ថានភាពក្បាលដី"។ ករណីនេះស្របតាមមាត្រា ២៣១ នៃច្បាប់ភូមិបាលដែលចែងថា អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រត្រូវកំណត់វិធី និង ស្តង់ដារទាក់ទងទៅនឹងឯកសារពត៌មានអំពីដីនេះ។ ការធ្វើផែនទីបឋមនេះ ក៏ជាការចាំបាច់ដើម្បីអនុវត្តមាត្រា ២៥៩ ដែលអនុញ្ញាតឱ្យរដ្ឋទទួលខុសត្រូវលើការកំណត់ការប៉ះពាល់កម្មសិទ្ធិនៃទ្រព្យសម្បត្តិសាធារណៈ។ម្យ៉ាងទៀត ផែនទី ឬប្រព័ន្ធទិន្នន័យដីរដ្ឋ នឹងផ្តល់នូវការសន្មត់តាមផ្លូវច្បាប់មួយអំពីកម្មសិទ្ធិរបស់រដ្ឋ។

ផែនទី ឬប្រព័ន្ធទិន្នន័យដីរដ្ឋជាផ្លូវការនឹងមានតែមួយគត់ ដែលអនុញ្ញាតដោយគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តក្រុង។ ឯកសារបច្ចេកទេសជាក់លាក់នៃការធ្វើផែនទី ឬប្រព័ន្ធទិន្នន័យ នឹងត្រូវបានអភិវឌ្ឍដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង ផ្អែកលើរូបថតពីអាកាសដែលមានភ្ជាប់ចំណុចប្រថពីវិភាគ (georeferenced remotely sensed images) នៃប្រទេសកម្ពុជា ក្នុងមាត្រដ្ឋានមួយសមស្រប និងមានសុក្រឹតភាព ដើម្បីឱ្យអ្នកប្រើប្រាស់កំណត់បានត្រឹមត្រូវ នូវព្រំប្រទល់ទូទៅនៃដីរដ្ឋ។ ផែនទី ឬ ប្រព័ន្ធទិន្នន័យដីរដ្ឋដែលនឹងត្រូវបានបង្កើតឡើង ដោយការគាំទ្របច្ចេកទេសពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នឹងត្រូវបានរក្សាទុកដោយអាជ្ញាធរខេត្តក្រុងក្នុងនាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការគ្រប់គ្រងផ្នែកបច្ចេកទេសពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ការធ្វើចរន្តការឯកសារចម្លងនៃផែនទី ឬប្រព័ន្ធទិន្នន័យដីរដ្ឋដោយអាជ្ញាធរខេត្តក្រុង នឹងត្រូវបានផ្ញើជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រុមប្រឹក្សាគោលនយោបាយដីធ្លី យ៉ាងហោចមួយឆ្នាំម្តង។ ផែនទី ឬ ប្រព័ន្ធទិន្នន័យនៃខេត្តក្រុងនីមួយៗ នឹងដាក់ផ្សាយជាសាធារណៈនៅគ្រប់ស្ថាប័នរដ្ឋ និងប្រជាពលរដ្ឋ សំរាប់ត្រួតពិនិត្យទៅតាមនីតិវិធីកំណត់ ហើយផែនទី ឬប្រព័ន្ធទិន្នន័យនេះ អាចផ្តល់ជូនតាមការស្នើសុំ ក្នុងតម្លៃមួយស្មើនឹងតម្លៃផលិតឡើងវិញ និង តម្លៃថែទាំទៅតាមបែបបទ និងទម្រង់ទិន្នន័យដែលនឹងកំណត់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ផ្នែកទី ៤ : ការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញ

ការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញមានន័យថា ការប្តូរឋានៈដីរបស់រដ្ឋ ក្រោយពីធ្វើការចុះបញ្ជី និងការធ្វើចំណាត់ថ្នាក់លើកដំបូង ដូចមានពណ៌នាខាងលើ។ ការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញមានបីប្រភេទគឺ : ១-ការធ្វើចំណាត់ថ្នាក់ទ្រព្យសាធារណៈរបស់រដ្ឋ ទៅជាទ្រព្យឯកជនរបស់រដ្ឋ ២-ការធ្វើចំណាត់ថ្នាក់ទ្រព្យសាធារណៈរបស់រដ្ឋពីការប្រើប្រាស់ជាប្រយោជន៍សាធារណៈមួយ ទៅជាប្រភេទបំរើប្រយោជន៍សាធារណៈមួយផ្សេងទៀត និង ៣-ការធ្វើចំណាត់ថ្នាក់ទ្រព្យឯកជនរបស់រដ្ឋ ទៅជាទ្រព្យសាធារណៈរបស់រដ្ឋ។

ការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញ ត្រូវបានធ្វើឡើងតាមរយៈសំណើជាលាយល័ក្ខអក្សរ ពីនីតិបុគ្គលសាធារណៈណាមួយទៅគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តក្រុង។ សំណើនេះត្រូវប្រកាស ឬបរិយាយអំពីទីតាំងដែលស្នើសុំធ្វើចំណាត់ថ្នាក់ឡើងវិញ ពាក្យស្នើសុំធ្វើចំណាត់ថ្នាក់ឡើងវិញ និងហេតុផលនៃការស្នើសុំធ្វើចំណាត់ថ្នាក់ឡើងវិញ។ គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីខេត្តក្រុង នឹងតំរូវឱ្យ**ស្ថាប័នបច្ចេកទេសជំនាញ**(ចំរុះមន្ទីរ) ធ្វើការពិនិត្យឡើងវិញនូវសំណើដែលស្នើឡើង ក្នុងរយៈពេល ៤៥ ថ្ងៃ។

ការពិនិត្យឡើងវិញជាលាយលក្ខណ៍អក្សរ ត្រូវពន្យល់ពីវិធីសាស្ត្រដែលបានប្រើក្នុងការត្រួតពិនិត្យ ហើយដែលវិធីសាស្ត្រនេះត្រូវរាប់បញ្ចូលទាំងពត៌មានដែលបានទទួលពីភាគីស្នើសុំ ទាំងលទ្ធផលរកឃើញក្នុងការត្រួតពិនិត្យ និង អនុសាសន៍របស់**ស្ថាប័នបច្ចេកទេសជំនាញ** ពាក់ព័ន្ធទៅនឹងសំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនេះ។ ការពិនិត្យឡើងវិញនេះត្រូវបញ្ចប់ក្នុងរយៈពេល៦០ថ្ងៃ គិតពីថ្ងៃចាប់ផ្តើមត្រួតពិនិត្យ លើកលែងតែមានការស្នើសុំពន្យាពេលបន្ថែមពីអ្នកត្រួតពិនិត្យ ដោយមានហេតុផលជាក់លាក់។ បន្ទាប់មក គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីខេត្តក្រុង នឹងធ្វើការសំរេចជាលាយលក្ខណ៍អក្សរលើការធ្វើចំណាត់ថ្នាក់ឡើងវិញនេះ (យល់ព្រម ឬ បដិសេធ ឬ កែសម្រួល) ក្នុងរយៈពេល៦០ថ្ងៃ គិតចាប់ថ្ងៃទទួលបានលទ្ធផលនៃការត្រួតពិនិត្យ។ ការកំណត់របស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តក្រុង នឹងត្រូវស្នើសុំការសំរេចជាផ្លូវការពីក្រុមប្រឹក្សាគោលនយោបាយដីធ្លី តាមរយៈអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី។

ការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញនេះនឹងត្រូវបញ្ចូលទៅក្នុងផែនទី ឬប្រព័ន្ធទិន្នន័យដីរដ្ឋ ហើយសេចក្តីសំរេចជាលាយលក្ខណ៍អក្សរត្រូវរក្សាទុកជាឯកសារ។

## ផ្នែកទី ៥ : ការគ្រប់គ្រង និង ការបែងចែកដីរដ្ឋ

រដ្ឋ និងនីតិបុគ្គលសាធារណៈផ្សេងៗ គឺជាម្ចាស់លើដីរដ្ឋទាំងអស់។ ដីសាធារណៈរបស់រដ្ឋ នឹងត្រូវគ្រប់គ្រងដោយក្រសួង ឬ ស្ថាប័ន ឬ អង្គភាពដែលមានអាណត្តិជាប់នឹងប្រយោជន៍សាធារណៈនោះ ឬជាប់នឹងការប្រើប្រាស់ជាសាធារណៈនូវតំបន់ជាក់លាក់ណាមួយនៃដីសាធារណៈរបស់រដ្ឋ។ ក្រសួង ឬ ស្ថាប័ន ឬ អង្គភាពនីមួយៗនឹងមានសិទ្ធិផ្ទេរអំណាចគ្រប់គ្រងទ្រព្យសាធារណៈរបស់រដ្ឋ ទៅឱ្យអង្គភាពសាធារណៈមួយបន្តទៀត ដោយផ្អែកលើកិច្ចសន្យាជាលាយល័ក្ខអក្សរនៃការទទួលខុសត្រូវគ្រប់គ្រង រាប់ទាំងលក្ខណៈជាក់លាក់នៃទ្រព្យដែលត្រូវផ្ទេរ ដោយយោងទៅតាមលក្ខខណ្ឌច្បាប់។

អនុក្រឹត្យនេះនឹងកំណត់នូវការរៀបចំស្ថាប័នគ្រប់គ្រងដីរដ្ឋ ដែលយកច្បាប់ភូមិបាល និងច្បាប់ពាក់ព័ន្ធដទៃទៀតមកពិចារណា។ ដីសាធារណៈរបស់រដ្ឋ នឹងត្រូវគ្រប់គ្រងដោយក្រសួង ឬអាជ្ញាធរដែលក្នុងអាណត្តិរបស់ខ្លួនមានពាក់ព័ន្ធនឹងផលប្រយោជន៍ ឬការប្រើប្រាស់ជាសាធារណៈ។ ដីឯកជនរបស់រដ្ឋ នឹងត្រូវគ្រប់គ្រងដោយគណៈកម្មាធិការប្រើប្រាស់ និងបែងចែងដីថ្នាក់ខេត្តក្រុង។ គណៈកម្មាធិការប្រើប្រាស់ និងបែងចែងដីថ្នាក់ខេត្តក្រុងត្រូវបានប្រគល់សិទ្ធិឱ្យមានមតិសំរេចលើទីតាំងសម្បទានដីសង្គមកិច្ច និងសម្បទានដីសេដ្ឋកិច្ច ស្របតាមនីតិវិធីដែលបានបង្កើតសំរាប់ការផ្ទេរដីនេះ។ គណៈកម្មាធិការប្រើប្រាស់ និងបែងចែងដី

ថ្នាក់ខេត្តនឹងមានអំណាចផ្ទេរការទទួលខុសត្រូវលើការគ្រប់គ្រងដីឯកជនរបស់រដ្ឋ ទៅឱ្យអង្គភាពសាធារណៈផ្សេងទៀត ប៉ុន្តែមិនអាចផ្ទេរសិទ្ធិលក់ ជួល ឬសិទ្ធិប្រគល់ដីទៅឱ្យអង្គភាពសាធារណៈដទៃទៀតឡើយ ។

គណៈកម្មាធិការប្រើប្រាស់ និងបែងចែងដីថ្នាក់ខេត្តនីមួយៗនឹងទទួលខុសត្រូវចំពោះការកសាងផែនការប្រើប្រាស់ដីថ្នាក់ខេត្តក្រុង ដែលបង្កើតផែនការប្រើប្រាស់ដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋសំរាប់អំឡុងពេល ២០ ឆ្នាំ។ ផែនការប្រើប្រាស់ដីទាំងនេះត្រូវតែបង្កើតឡើង ដោយការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំសង្កាត់ និងត្រូវបានទទួលការយល់ព្រមពីក្រុមប្រឹក្សាគោលនយោបាយដីធ្លី។ គ្មានការប្រើប្រាស់ដីរដ្ឋផ្ទុយពីផែនការប្រើប្រាស់ដី អាចត្រូវបានអនុញ្ញាតឡើយ។ ប៉ុន្តែ ផែនការប្រើប្រាស់ដីនេះក៏អាចធ្វើការកែប្រែបានដោយគណៈកម្មាធិការប្រើប្រាស់ និងបែងចែងដីខេត្តក្រុង ក្រោមការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំសង្កាត់ និង ដោយគ្មានការជំទាស់ពីក្រុមប្រឹក្សាគោលនយោបាយដីធ្លី។

**ការបែងចែកដី**នៅក្នុងបរិបទនេះ មានន័យថា ជាការចាត់ចែងដីរបស់រដ្ឋសំរាប់គោលដៅផ្សេងៗ ។ មានតែដីឯកជនរបស់រដ្ឋប៉ុណ្ណោះ ដែលអាចធ្វើការបែងចែកបាន ។ ដីសាធារណៈរបស់រដ្ឋ អាចធ្វើការបែងចែកបានលុះត្រាតែបានធ្វើចំណាត់ថ្នាក់ឡើងវិញមកជាដីឯកជនរបស់រដ្ឋជាមុនសិន។ ដោយហេតុថា ដីត្រូវតែធ្វើចំណាត់ថ្នាក់ឱ្យទៅជាដីឯកជនរបស់រដ្ឋ ហើយមុននឹងធ្វើចំណាត់ថ្នាក់ ដីនេះត្រូវតែបានចុះបញ្ជីជាមុនសិន។ ដូច្នេះ គឺមានតែដីឯកជនរបស់រដ្ឋដែលបានចុះបញ្ជីរួចហើយទេ ដែលអាចបែងចែកបាន ។ ដីឯកជនរបស់រដ្ឋអាចបែងចែកសំរាប់ការប្រើប្រាស់ជាទ្រព្យរដ្ឋ ជាទ្រព្យខេត្តក្រុង ឬជាទ្រព្យសហគមន៍ និងសំរាប់អង្គភាពឯកជន។ ការបែងចែកសំរាប់អង្គភាពឯកជន អាចធ្វើទៅបានតាមរយៈសម្បទាន ដោយអនុលោមតាមអនុក្រឹត្យពាក់ព័ន្ធ ឬតាមរយៈភតិសន្យា (ការជួល) ដែលនឹងពណ៌នានៅក្នុងអនុក្រឹត្យនេះ។ យោងតាមច្បាប់ភូមិបាល ដីឯកជនរបស់រដ្ឋអាចជាកម្មវត្ថុនៃភតិសន្យា។ បទបញ្ញាបច្ចុប្បន្ននៃភតិសន្យា(ការជួល) គឺផ្អែកលើបទបញ្ជាលេខ ៣០ បប/១៩៩៧។

## ផ្នែកទី ៦: ការលក់ដីរដ្ឋ

ជាវិធីមួយផ្សេងទៀតជំនួសឱ្យការបែងចែកដីគឺ ដីរដ្ឋដែលបានចុះបញ្ជី និងធ្វើចំណាត់ថ្នាក់ជាដីឯកជនរបស់រដ្ឋរួចហើយ អាចលក់បាន។ យោងតាមច្បាប់ភូមិបាល ការលក់ និងការផ្លាស់ប្តូរដីឯកជនរបស់រដ្ឋ អាចធ្វើបានតែតាមរយៈអនុក្រឹត្យប៉ុណ្ណោះ ។ ដូច្នេះ បញ្ញត្តិទាំងឡាយនៃការលក់ និងការផ្លាស់ប្តូរដី គួរតែបញ្ចូលទៅក្នុងអនុក្រឹត្យនេះ ។ បទបញ្ញាបច្ចុប្បន្ននៃការលក់ គឺផ្អែកលើបទបញ្ជាលេខ ៣០ បប/១៩៩៧ ។

## ផ្នែកទី ៧: ការតាមដានត្រួតពិនិត្យ និងការពង្រឹងការអនុវត្តន៍

ស្ថាប័នរដ្ឋនីមួយៗដែលមានការទទួលខុសត្រូវលើការគ្រប់គ្រងការប្រើប្រាស់ដី នឹងមានការទទួលខុសត្រូវចំពោះការតាមដានត្រួតពិនិត្យ និងការពង្រឹងបូរណភាពដីដែលស្ថិតក្រោមយុត្តាធិការរបស់ខ្លួន ឱ្យបានស្របទៅតាមច្បាប់ ។

ផែនទី ឬប្រព័ន្ធទិន្នន័យដីរដ្ឋ និងសៀវភៅគោលបញ្ជីចលនទ្រព្យ នឹងផ្តល់នូវប្រវត្តិការកាន់កាប់ដីរបស់រដ្ឋ និងប្រើជាភស្តុតាងសំរាប់ករណីដែលមានការរំលោភបំពាន។ ប្រជាពលរដ្ឋ អង្គភាពសាធារណៈ ឬអង្គការដែលបានចុះបញ្ជីហើយ មានសិទ្ធិដាក់ពាក្យបណ្តឹងទៅតុលាការ អំពីការប្រើប្រាស់ដីមិនសមស្រប ។

រាល់ការលក់ដីសាធារណៈរបស់រដ្ឋ ឬប្រើប្រាស់ខុសពីផលប្រយោជន៍សាធារណៈដែលបានកំណត់ត្រូវបានហាមឃាត់ ហើយនឹងត្រូវអនុវត្តការដាក់ទណ្ឌកម្មតាមរដ្ឋប្បវេណី ។